អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ ល្បែងបើកកាតសំរាម

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្រ្ត** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម៖

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ៖

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ៖

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យាករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ៖

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្រ្ត** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីកន្លែងទុកដាក់សំរាមទៅតាមការកំណត់។

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។

បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតមានពីរប្រភេទ។ កាតធុងសំរាមមាន៥ប្រភេទ (ពណ៌ / សខ្មៅ)

កាតធុងសំរាម៥ប្រភេទ៥ពណ៌ (ពណ៌ / សខ្មៅ)។ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង ៣. ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទិក និង ៥.

ពណ៌ក្រហមសំណល់គ្រោះថ្នាក់ ) ជាទំហំA4។

កាតរូបភាពសំរាមតូចៗដែលមានរូបភាពសំរាមតាមធុងសំរាមនីមួយៗ ដែលកាត់វា និងអ៊ុតវាឱ្យបានស្អាតផងដែរ។

និងស្កុតសម្រាប់បិទ។ កាតទាំងអស់ត្រូវកាត់និងអ៊ុតវាឱ្យបានស្អាតនិងរឹងមាំផងដែរ។

**ការរៀបចំ** ៖ ត្រូវត្រៀម សម្ភារសម្រាប់លេងល្បែងនេះឱ្យបានគ្រប់គ្រាន់ ល្បែងនេះអាចលេងម្តងម្នាក់បាន។

**សេចក្តីណែនាំ** ៖

1. មុននឹងលេងល្បែងនេះ ត្រូវសួរកុមារសំណួរមួយចំនួនសិន។
2. សំណួរអាចមានដូចជា៖ តើកូនៗស្គាល់សំរាមដែរឬទេ? សំរាមមានអ្វីខ្លះ? សំរាមមានប៉ុន្មានប្រភេទ?
3. បន្តិចទៀត យើងនឹងលេងល្បែងសកម្មភាពមួយដែលមានឈ្មោះថា ល្បែងបើកកាតសំរាម។
4. គ្រូត្រូវបង្ហាញកាតធំ ជាធុងសំរាម នីមួយៗទៅកាន់កុមារ និងពន្យល់ពួកគេឱ្យបានស្គាល់និងយល់ពីសំរាមឱ្យបានច្បាស់ជាមុនសិន មុននឹងចាប់ផ្តើមលេងល្បែងនេះ
5. និងប្រាប់កាត់តូចៗដូចគ្នាដែរ ប្រាប់កុមារថាសំរាមណា ត្រូវនៅក្នុងធុងសំរាមណា ជាដើម…។
6. ពន្យល់ពីរបៀបលេងល្បែងនេះជាមុនសិន
   - ល្បែងនេះលេងទាំងអស់គ្នា មានន័យថាលេងម្នាក់ៗបាន
   - ដំបូងគ្រូត្រូវបិទកាតធំធុងសំរាម នៅលើក្តារខៀន ជា៥កន្លែងដែលមានចន្លោះពីគ្នាល្មម។
   - បន្ទាប់មក កាតតូចដែលបានកាត់រួច (កាតដែលមាបរូបសំរាម) ត្រូវដាក់ផ្កាប់នៅលើតុមួយ
   - គ្រូហៅកូនសិស្ស១នាក់ឡើងមកខាងលើ និងប្រាប់កុមារនោះឱ្យបើកកាត់មួយសន្លឹក ហើយមើលថាជាកាតសំរាមអ្វី? បន្ទាប់មក កុមារនោះត្រូវប្រាប់គ្រូថាកាតសំរាមនោះត្រូវដាក់ក្នុងធុងសំរាមមួយណា ដែលបានបិទនៅលើក្តារខៀននោះ?
   - បើកុមារអាចដឹងនិងបិទបាន ឱ្យគេប្រើស្កុតទៅបិទបាន បន្ទាប់ពីបិទរួចគ្រូត្រូវពិនិត្យជាមួយកុមារផ្សេងទៀតក្នុងថ្នាក់ទាំងអស់ ថាត្រឹមត្រូវដែរឬទេ? ប្រសិនបើត្រូវហើយ ត្រូវមានសំលេងទះដៃសម្រាប់កុមារនោះ តែប្រសិនបើខុស គ្រូអាចហៅកុមារម្នាក់ទៀតមក បកនិងបិទក្នុងធុងសំរាមដែលត្រឹមត្រូវ តែបើនៅតែមិនទាន់ត្រឹមត្រូវទៀត គ្រូអាចសួរកុមារទាំងអស់ក្នុងថ្នាក់បានផងដែរ។

- មួយទៀត ប្រសិនបើកុមារដែលបើកកាតហើយ
មិនដឹងថាកាតសំរាមនោះត្រូវដាក់នៅធុងសំរាមណានោះ កុមារអាចឱ្យមិត្តរួមថ្នាក់ជួយបាន
ដោយស្រែកសួរពួកគេបានផងដែរ។
- ពេលដឹងធុងសំរាមណាហើយ កុមារនោះអាចបិទកាតសំរាមនោះឱ្យបានត្រឹមត្រូវជាការស្រេច។
- គ្រូលេងបែបនេះ ហៅបែបនេះរហូតដល់អស់ម៉ោង
ឬគ្រប់គ្នាជាការស្រេចសម្រាប់ការលេងល្បែងសកម្មភាពមួយនេះ។

7. នៅពេលដែលលេងរួចរាល់
គ្រូអាចប្រាប់កុមារឱ្យជួយរៀបចំកាតឬសម្ភារដែលលេងល្បែងទុកឱ្យមានសណ្តាប់ធ្នាប់ផង
ជាទំលាប់ល្អសម្រាប់កុមារក្នុងថ្នាក់ផងដែរ ប៉ុណ្ណឹងជាការស្រេច។